ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

# រយៈពេល ៣ ឆ្នាំ

# (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : កោះឬស្សី

ភូមិ : កោះឬស្សី

ឃុំ : ប្រឡាយមាស

ស្រុក : កំពង់លែង

ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
## រយៈពេល ៣ ឆ្នាំ
## (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : កោះឬស្សី
ភូមិ : កោះឬស្សី
ឃុំ : ប្រឡាយមាស
ស្រុក : កំពង់លែង
ខេត្ត : កំពង់ឆ្នាំង

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ កោះឫស្សីត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **១៩** ខែ **ឧសភា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ច ព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។ សហគមន៍នេសាទ កោះឫស្សីមានទីតាំងស្ថិត នៅក្នុងភូមិ **កោះឫស្សី** ឃុំ **ប្រឡាយមាស** ស្រុក **កំពង់លែង** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **២៣៩** នាក់ ស្រីចំនួន **១២៣** នាក់ និងមានគណៈកម្មការចំនួន **១១** នាក់។ ក្នុងនោះចំនួនគ្រួសារ ដែលចូលជាសមាជិកសហគមន៍ នេសាទសរុបមានចំនួន **១៧២** គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន ឆ្នាំ ២០០២ ប្រជាពលរដ្ឋបានផ្តិតមេដៃស្នើសុំឱ្យមានការបង្កើតសហគមន៍នេសាទយោងលើរាជរដ្ឋាភិបាលធ្វើកំណែទំរង់វិស័យជលផលសហគមន៍នេសាទក៏បានកើតឡើងតាមរយៈការបោះឆ្នោតជ្រើសរើសគណៈកម្មការដោយមានការជួយគាំទ្រពី ការិយាល័យជល-ផលខេត្ត អាជ្ញាធរមូលដ្ឋាន នៅឆ្នាំ ២០០៣ មានការផ្សព្វផ្សាយពីច្បាប់ជលផល មានការចុះល្បាតដើម្បីទប់ស្កាត់បទល្មើសនេសាទ និងទប់ស្កាត់បានទាំងស្រុងលើការប្រើប្រាស់ឧបករណ៍ស្បៃមុង នៅឆ្នាំ ២០០៤ សហគមន៍នៅតែមានសកម្មភាពផ្សព្វផ្សាយ ប្រជុំស្តីពីការងារពង្រឹងផ្នែកគ្រប់គ្រង ជាមួយប្រជាពលរដ្ឋក្នុងភូមិ និងចូលរួមរៀនសូត្រលើវគ្គបណ្តុះបណ្តាលផ្នែករដ្ឋបាល នៅឆ្នាំ ២០០៥ មានការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទបន្ថែមឱ្យបានចំនួន១១រូប បង្កើតឱ្យមានក្រុមល្បាត ចូលរួមរៀនសូត្រផ្នែករដ្ឋបាល សិក្សាវាយតម្លៃលើមុខរបរចិញ្ចឹមជីវិត នៅឆ្នាំ ២០០៦ ផ្សព្វផ្សាយអនុក្រឹត្យសហគមន៍នេសាទ ចុះឈ្មោះសមាជិកសហគមន៍នេសាទ កំណត់ព្រំប្រទល់ផែនទីសហគមន៍ បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងធនធានជលផល និងការប្រើប្រាស់ថ្នាំពុល នៅឆ្នាំ ២០០៧ រៀបចំធ្វើលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ធ្វើមហាសន្និបាតដើម្បីអនុម័តលើលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង សមាជិកភាព ផែនទី និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ប្រជុំប្រចាំខែរបស់សហគមន៍នេសាទ និងចុះល្បាតលើដែននេសាទសហគមន៍។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន **៧៤៥** នាក់ប្រុស **៣៤៦** នាក់ ស្រី **៣៩៩** នាក់ ដែលជាជនជាតិខ្មែរ
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១០ នាក់
- ចំនួនស្ត្រីពោះម៉ាយក្នុងសហគមន៍នេសាទមាន ២ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៤ នាក់ ជាបុរស

- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៥ នាក់ ស្រី ២ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៤ នាក់ ស្រី ២នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ៤ នាក់ ស្រី ៤ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០% ។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ១៦៩ នាក់ ស្រី ១១១ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន ២១២ នាក់ ស្រី ១២១ នាក់ កំរិតមធ្យមសិក្សា ចំនួន ៧ នាក់ ស្រី គ្មាន និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន ២ នាក់ ស្រី ១ នាក់ ។

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- ធ្វើចំការ ( សណ្តែក ពោត ឪឡឹក) ចំនួន ៧៤គ្រួសារ ដែលមានទំហំដី ១៤១ ហិកតា
- ធ្វើនេសាទចំនួន ៧៤ គ្រួសារ ក្នុងរដូវត្រីចំណុះ
- ធ្វើស្រែប្រាំងចំនួន ៣០ គ្រួសារ ទំហំ ២៨ ហិកតា
- កែច្នៃផលនេសាទចំនួន ៧៤ គ្រួសារ នៅខែ មករា ដល់ខែ ឧសភា ដែលជាមធ្យមក្នុង ១ គ្រួសារ ៣០០ គក្រ ត្រីស្រស់
- ចិញ្ចឹមសត្វ ចំនួន ២៥ គ្រួសារ ដែលមានជ្រូក ៤០ក្បាល មាន់ ២០០ក្បាល ទា ២៥០ក្បាល
- កែច្នៃផលិតផលកសិកម្ម( ម្ទេសហាល) ចំនួន ៥០គ្រួសារ ដែលជាមធ្យមធ្វើបាន២០គកស្ងួតក្នុង១គ្រួសារ
- ធ្វើឧបករណ៍នេសាទចំនួន ៨ គ្រួសារ ( លប ព្រួល)
- ផលិតពូជបន្លែលក់ចំនួន ៦០ គ្រួសារដែលជាមធ្យមរកប្រាក់បាន៦០ ម៉ឺនរៀលក្នុង១គ្រួសារ
- ច្រូតស្មៅលក់ចំនួន ១០ គ្រួសារ ដែលជាមធ្យមរកប្រាក់បាន១៦ ម៉ឺនរៀលក្នុង១គ្រួសារ
- ធ្វើថែបលក់ចំនួន ២ គ្រួសារ
- ជួសជុលកាណូតចំនួន ២ គ្រួសារ
- ទិញលក់បន្លែចំនួន ២ គ្រួសារ
- ជាងផ្សាដែកចំនួន ២ គ្រួសារ
- លក់កំលាំងពលកម្មចំនួន ១០ គ្រួសារ
- ជាងប៉ះកង់ចំនួន ១ គ្រួសារ
- ជាងកាត់ដេរក្នុងភូមិចំនួន ៥ គ្រួសារ
- ឆ្មបបុរាណចំនួន ១ គ្រួសារ
- ជាងកាត់សក់ចំនួន ៣ គ្រួសារ

- តម្បាញកន្ទេលក្រហមចំនួន ២ គ្រួសារ
- ម៉ាស៊ីនកិនស្រូវចំនួន ១ គ្រួសារ
- ពេទ្យចំនួន ១ គ្រួសារ
- ធ្វើការរោងចក្រចំនួន ១៥ គ្រួសារ
- បញ្ចូលអាគុយ ២ គ្រួសារ
- លក់ដូរចំនួន ៥ គ្រួសារ
- ជាងសំនង់ផ្ទះថ្មចំនួន ២ គ្រួសារ
- ជាងផ្ទះឈើចំនួន ៣ គ្រួសារ
- ជួលមេក្រូ និងម៉ាស៊ីនភ្លើងចំនួន ២ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍កោះឫស្សី ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ **៧**។ កន្លែងនេសាទសហគមន៍ **កោះឫស្សី** មានទំហំ **២៥២** ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងហើយមានព្រំប្រទល់ :

- ខាងជើងទល់នឹង **ដើមរាំងមួយដើមចំការតាវ៉ាត់**
- ខាងត្បូងទល់នឹង **ចុងកោះព្រៃកកាត់ខាងលិច**
- ខាងកើតទល់នឹង **ដើមរាំងចំការតាវ៉ាត និងវែ៉តស្រួយ**
- ខាងលិចទល់នឹង **ចុងកោះព្រៃកកាត់ខាងលិច**

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ **កោះឫស្សី** មានបឹងចំនួន ១ ត្រពាំងចំនួន ១ និងព្រៃលិចទឹកព័ទ្ធជុំវិញមាត់បឹង។

- បឹងឈ្មោះ **អន្លង់កេះ** ទំហំ ២៥០៣៧ ម៉ែត្រក្រលា នេសាទពីខែ មករា ដល់ខែ ធ្នូ
- ត្រពាំងឈ្មោះ **តាឪ** ទំហំ ២០ គុណ ១០ ស្មើ ២០០ ម៉ែត្រក្រលា នេសាទពីខែ សីហា ដល់ខែ មិនា
- ព្រៃលិចទឹកមានទំហំ **១៥៨៤** គុណ ៤ ស្មើ៦៣៣៦ ម៉ែត្រក្រលាដែលលិចទឹកនៅ ខែ សីហា ដល់ខែ មករា
- ដីទំនាបលិចទឹកមានទំហំសរុប **២៥២** ហិកតា ដែលលិចទឹកនៅ ខែ ៨-ដល់ខែ ១។

### គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- បឹងឈ្មោះ **អន្លង់កេះ** ទំហំ .ហិកតា ( បណ្តោយ ២៥០ ម ទទឹង ១២ ម)

## ឃ. ធនធានជលផល

### តារាងឧបសម្ព័ន្ធទី១ ធនធានជលផលក្នុងកន្លែងនេសាទសហគមន៍

| លរ | ត្រី | | | វារីសត្វ | | | វារីរុក្ខជាតិ | | | ព្រៃលិចទឹក | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឈ្មោះត្រី | កើន | ថយ | ឈ្មោះវារីសត្វ | កើន | ថយ | ឈ្មោះវារីជាតិ | កើន | ថយ | ឈ្មោះព្រៃលិចទឹក | កើន | ថយ |
| ១ | រ៉ស់ | -- | | ភេ | | — | កំប្លោក | -- | | រាំង | -- | |
| ២ | ដំរី | | — | ពស់ព្រលិត | -- | | ត្រកួន | | — | ច្រកែង | | — |
| ៣ | ឆ្ដោ | | — | ខ្យង | -- | | កន្ទាំងហែ | | — | ទន្លា | | — |
| ៤ | កន្ទ្រប់ | -- | | អណ្ដើក | | — | កំពឹងពួយ | | — | ទ្រៀនព្រៃ | -- | |
| ៥ | រៀល | -- | | លៀស | -- | | ស្មៅ | -- | | ត្រស់ | | — |
| ៦ | អណ្ដែង | | — | ខ្ចៅ | -- | | ស្លូង | | — | អាញៀវ | -- | |
| ៧ | កញ្ជនជ័យ | | — | មាន់ទឹក | | — | ចក | | — | ស្លូត | -- | |
| ៨ | ក្រុស | -- | | អែអូត | | — | សារ៉ាយ | | — | ញរ | -- | |
| ៩ | ខ្នាន់ | -- | | កុក | -- | | ស្លាបទា | -- | | ត្រែទឹក | -- | |
| ១០ | កញ្ចុះ | -- | | ទាព្រៃ | | — | ស្មៅរំពាក់ទឹក | -- | | បបុស | | — |
| ១១ | ក្រមំម | | — | ក្អែកទឹក | -- | | ស្មៅពក | | — | អញ្ចាញ | | — |
| ១២ | ប្រម៉ា | | — | ក្អែកគោក | | — | ស្មៅចាផ្លង | -- | | ភ្អែកព្រាប | | — |
| ១៣ | កាហែ | -- | | ប្រវឹក | | — | ស្មៅរពាក់ទឹក | -- | | ឆ្អឹងពស់ | | — |
| ១៤ | ច្រឡឹង | -- | | ពស់ឈើ | -- | | ស្មៅអញ្ចៀន | | — | ប្រផិញ | | — |
| ១៥ | ក្រាញ់ | -- | | ពស់សំលាប់កង្កែប | -- | | | | | ផ្ទៅល | | — |
| ១៦ | កំភ្លាញ | -- | | ពស់ត្រី | | — | | | | សណ្ដាន់ | | — |
| ១៧ | កន្ធរ | | — | ពស់ថ្លាន់ | | — | | | | ត្រសេក | | — |
| ១៨ | អំពិលទុំ | | -- | ពស់ក្រាយ | | — | | | | វិរជុយ | | — |
| ១៩ | ស្រកាក្ដាម | -- | | លលក | -- | | | | | វិរប្រេង | | — |
| ២០ | កន្ទ្រងប្រេង | -- | | ក្រដេវិច | -- | | | | | ខ្ទម | | — |
| ២១ | កញ្ជ្រាញ់ច្រាស | -- | | ខ្លែង | | -- | | | | អួយមួយ | | — |
| ២២ | អន្ទង់ | | -- | ទុង | -- | | | | | បាយស្អិត | | — |
| ២៣ | ខ្ទឹង | | — | គួក | -- | | | | | ប្រទ្បាយួន | -- | |
| ២៤ | ឆ្លូញ | | — | មៀម | | — | | | | ថ្កូវ | | — |
| ២៥ | លលកសរ | | -- | ខ្លាត្រី | | — | | | | អណ្ដាតត្រកួត | | — |
| ២៦ | ឆ្ពិន | -- | | សំពោច | -- | | | | | ត្រដិត | | — |
| ២៧ | សង្កត់ប្រាក់ | -- | | សារិកាកែវ | | | | | | វិរដូងព្រះ | | — |
| ២៨ | ស្លាត | | — | សេក | | | | | | វិររនោងព្រៃ | | — |
| ២៩ | ក្រាយ | | — | ទីទុយ | | | | | | ភ្នំភ្លេង | | — |
| ៣០ | ច្រកែង | -- | | ក្រលីងក្រលោង | | | | | | ដើមក្របៅ | | — |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣១ | ឆ្លាំង | —— | | កដប | | | | | | ខ្នាយមាន់ | —— | |
| ៣២ | កំភ្លាវ | -- | | ត្រសេះ | | | | | | អាវក្រពើ | —— | |
| | | | | ខ្លែងស្រាក់ | | | | | | សាម៉ាវព្រៃ | —— | |
| | | | | ត្រដក់ | | | | | | ក្រចកអណ្ដើក | —— | |
| | | | | កង្កែប | | | | | | ប្រលាខ្លែ | | —— |
| | | | | កំពិស | -- | | | | | | | |

- ប្រភេទត្រី ( ត្រីរ៉ស់ ឆ្តោ រៀល...)
- ប្រភេទវារីរុក្ខជាតិ ( កំប្លោក ស្មៅទឹក...)
- ប្រភេទវារីសត្វ ( អណ្តើក ពស់ ក្តាម...)
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ (រាំង ត្រស់ ត្នួ....) (ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី ១ ភ្ជាប់មកជាមួយ) ។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទអាជីពមានចំនួន ១៥ នាក់
- អ្នកនេសាទជាសមាជិកសហគមន៍នេសាទអាជីពមានចំនួន ២២៤ នាក់មានស្រី ១២៣ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ១២០ នាក់ គ្មាន
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៣២ នាក់ ស្រី គ្មាន (អ្នកដែលមកពីក្រៅមានដូចជា ភូមិ ស្ទឹងស្ងួត កំពង់ឆ្នាំង ក្រពើពុល កោះក្របី ប្រឡាយមាស តាដោក ជីក្រែង កោះថ្កូវ (ស្រុកជលគីរី) អូររលំ **ខ. ឧបករណ៍នេសាទ**

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍:

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ, ប្រវែង** | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មងពាក់ | ១ដៃ=៧០ម | ២ដៃx ៣៥នាក់= | ចំនួន=៤៩០០ម<br>ក្រឡា=២,៥-៦,៥សម<br>ជំរៅ=១,៥ម | សីហា ដល់ខែ វិច្ឆិកា |
| សន្ទូចរនង | ផ្លែ | ១៥០ផ្លែx ១៥នាក់= | ចំនួន=២២៥០ផ្លែលេខ១៥ | សីហា ដល់ខែ វិច្ឆិកា |

| | | | | |
|---|---|---|---|---|
| លប | គ្រឿង | ៥គ្រឿងx ១៥នាក់= | ចំនួន=៧៥គ្រឿង<br>ក្រឡាគ្រៀម=៣សម<br>កំពស់=១,២ម<br>មុខកាត់=0,៦ម | កុម្ភៈ ដល់ខែ មេសា |
| សៃយ៊ុនកំពិស | គ្រឿង | ៥០គ្រឿងx១០នាក់= | ចំនួន=៥០០គ្រឿង | សីហា ដល់ខែ តុលា |
| សំណាញ់ | វង់ | ១វង់x៣នាក់= | ចំនួន=៣វង់ | កុម្ភៈ ដល់ខែ មេសា |
| អង្រុត | គ្រឿង | ១គ្រឿងx៥នាក់= | ចំនួន=៥គ្រឿង | មិនា ដល់ខែ ឧសភា |
| លាន់ | គ្រឿង | ៣០គ្រឿងx១០នាក់= | ចំនួន=៣០០គ្រឿង | កុម្ភៈ ដល់ខែ សីហា |
| ថ្នងដងអន្ទុង | វង់ | ១វង់x៥នាក់= | ចំនួន=៥វង់ | តុលា ដល់ខែ វិច្ឆិកា |
| ច្បូក | គ្រឿង | ១គ្រឿងx៥នាក់= | ចំនួន=៥គ្រឿង | កញ្ញា ដល់ខែ វិច្ឆិកា |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកចែវ | ៩៥គ្រឿង | ១ តោន | |
| ទូកចែវ | ១០គ្រឿង | ១-៣ តោន | |
| មានម៉ាស៊ីន | ២៥ | ១ តោន | ៥សេះ |
| មានម៉ាស៊ីន | ៣៥ | ១-៣ តោន | ១០ -១៥សេះ |
| មានម៉ាស៊ីន | ១០ | ៣ តោនឡើង | ១៥-២០សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទៈ

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ, ប្រវែង** |
|---|---|---|---|
| មង | ១ដៃ=៨០ម | ១ដៃx ២០នាក់= | ចំនួន=១៦០០ម , ក្រឡា=២,៥-៦,៥សម<br>ជំរៅ=១,៥ម |
| សន្ទូចរនង | ផ្លែ | ៣០០ផ្លែx ២០គ្រួសារ | ៦០០០ផ្លែ |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូកភ្ជាប់ម៉ាស៊ីន | ១០ គ្រឿង | ១០០០គក្រ-១២០០គក្រ | ៥-៦សេះ |
| ទូកចែវ | ២០ គ្រឿង | ៥០០គក្រ | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ, ប្រវែង |
|---|---|---|---|
| មងរាយ | ១ដៃ=៧០ម | ២ដៃx ២៥នាក់= | ចំនួន=៣៥០០ម,ក្រឡា=២,៥-៦,៥សម ជំរៅ=១,៥ម |
| ទ្រូកំពីស | គ្រឿង | ៥គ្រឿងx ១០នាក់= | ចំនួន=៥០គ្រឿង |
| ប៉ោង | គ្រឿង | ៨គ្រឿងx ២នាក់= | ចំនួន=១៦គ្រឿង |
| ថ្នងអន្ទង់ | វង់ | ១វង់x ១៨= | ចំនួន=១៨វង់ |
| លប | គ្រឿង | ៤គ្រឿងx ១០នាក់= | ចំនួន=៤០គ្រឿង ,ក្រឡាគ្រៀម=៣សម កំពស់=១,២ម , មុខកាត់=០,៦ម |
| លបចេប | គ្រឿង | ៣គ្រឿងx ១៣នាក់= | ចំនួន=៣៩គ្រឿង |
| លាន់ | គ្រឿង | ៤០គ្រឿងx ១៥នាក់= | ចំនួន=៦០០គ្រឿង |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកម៉ាស៊ីន | ៧៣គ្រឿង | ៨០០ គក្រ-១២០០ម | ៥សេះ-១០សេះ |
| ទូកចែវ | ១០គ្រឿង | ៥០០ គក្រ | |
| ទូកគ្នោត | ៥គ្រឿង | ៥០ គក្រ | |

| ឈ្មោះឃុំពាក់ពន្ធ័ | ចំនួនអ្នកនេសាទមកពីខាងក្រៅ (នាក់) | ចំនួនទូកកាណូត | | | |
|---|---|---|---|---|---|
| | | តិចជាង១តោន | ១-៣ តោន | ៣ តោន | សរុប |
| ឃុំកំពង់ឆ្នាំង | ១០ | ១០ | ០ | ០ | ១០ |
| ឃុំកោះថ្កូវ | ១០ | ១០ | ០ | ០ | ១០ |
| ឃុំបឡាយមាស | ៣ | ៣ | ០ | ០ | ៣ |
| ឃុំកោះក្របី | ២ | ២ | | | ២ |
| ភូមិស្ទឹងស្លូត | ១០ | ១០ | | | ១០ |
| ឃុំអូររលំ | ៥ | ៥ | | | ៥ |
| ឃុំតាដោក | ១៥ | ១៥ | ០ | ០ | ១៥ |
| ឃុំជីក្រែង | ៦ | ៦ | ០ | ០ | ៦ |
| ភូមិក្រពើពុល | ១០ | ១០ | ០ | ០ | ១០ |

## គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ៦២០០គក្រ | ៥៤០០គក្រ | ១១៦០០ គក្រ |

## ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ (ធ្វើតាមក្រុមសាសធំ)

| ឧបករណ៏នេសាទ | ចំនួនត្រីចាប់បានប្រចាំរដូវ (គិតជា គ.ក) | | | | | | | | | | | | ចំនួនត្រីចាប់បានប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | រដូវប្រាំង | | | | | | រដូវវស្សា | | | | | | |
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | |
| មងពាក់ | | | | | | | | ៨០ថ្ងៃ x ៣គ.កក្នុងថ្ងៃ x ៤០គ្រួសារ | | | | | ៩៦០០ |
| សន្ទូចរនង | | | | | | | | ៦៤ថ្ងៃ x ២.៥គ.កក្នុងថ្ងៃ x ១០គ្រួសារ | | | | | ១៦០០ |
| សៃយ៉ឺន | | | | | | | | ៦០ថ្ងៃ x ២.៣គ.កក្នុងថ្ងៃ x ១០គ្រួសារ | | | | | ១៣៨០ |
| លបចេប | | ៩០ថ្ងៃ x ០.៧៥.គ.កក្នុងថ្ងៃ x ៥គ្រួសារ | | | | | | | | | | | ៣៣៧.៥ |
| សំណាញ់ | | ៤៥ ថ្ងៃ x ១.៥.គ.កក្នុងថ្ងៃ x ៣គ្រួសារ | | | | | | | | | | | ៦៧.៥ |
| អង្រុត | | | ៣០ ថ្ងៃ x ៥.គ.កក្នុងថ្ងៃ x ៥គ្រួសារ | | | | | | | | | | ១៥០ |
| លាន់ | | | | | | | ២០ ថ្ងៃ x ២.៥គ.កក្នុងថ្ងៃ x ១គ្រួសារ | | | | | | ៥០ |
| ថ្នងដងអន្ទង់ | | | | | | | | | | ១០ ថ្ងៃ x ២.គ.កក្នុងថ្ងៃ x ៣គ្រួសារ | | | ៦០ |
| សាង | | | | | | | | | ១២ថ្ងៃ x ០.៥.គ.កក្នុងថ្ងៃ x ១០គ្រួសារ | | | | ៦០ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៏នេសាទ **កោះឫស្សី** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

## ៩. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។
ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងអន្លង់កេះ | ខែ ៨-១១ | មងពាក់ | ៥៦០០ ម៉ែត្រ | ៤០នាក់ | ១នាក់ប្រើ១៤០ម |
| | ខែ ៨-១១ | សន្ទូចរនង | ១០០០ ផ្លែ | ១០នាក់ | ១នាក់ប្រើ១០០ផ្លែ |
| | ខែ ៨-១០ | សៃយ៉ឺន(ទ្រុងកំពិស) | ៣០០គ្រឿង | ១០នាក់ | ១នាក់ប្រើ៣០គ្រឿង |
| | ខែ ២-៤ | សំណាញ់ | ៣វង់ | ៣នាក់ | ១នាក់ប្រើ១វង់ |
| | ខែ ៣-៥ | អង្រុត | ៥គ្រឿង | ៥នាក់ | ១នាក់ប្រើ១គ្រឿង |
| | ខែ ៧-៨ | លាន់ | ១០០គ្រឿង | ៥នាក់ | ១នាក់ប្រើ២០គ្រឿង |
| | ខែ ១០-១១ | ថ្នងដងអន្ទង់ | ៣វង់ | ៣នាក់ | ១នាក់ប្រើ១វង់ |
| | ខែ ៩-១១ | ច្បូក | ៥គ្រឿង | ៥នាក់ | ១នាក់ប្រើ១គ្រឿង |
| | ខែ ២-៤ | លបចេប | ២៥គ្រឿង | ៥នាក់ | ១នាក់ប្រើ៥គ្រឿង |

## គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| គ្មាន | គ្មាន | គ្មាន | គ្មាន | | | |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងកេះ | ២៥០ម x ៣៥ម | អភិរក្សមេពូជ | បោះបង្គោល ដាក់លូ.ដាក់គល់ឈើ ខ្សែលួសព័ទ្ធជុំវិញ | កុម្ភៈ ២០០៩ | មេសា ២០១០ | កំពុងរកដៃគូជួយ |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹក មាត់បឹងអន្លង់កេះ | ១៥ម x ១០០០ម | រាំង ត្រស់ ច្រកែង(១ម៉ឺនកូន) | បណ្តុះកូនឈើ និងដាំដុះ | កក្កដា ២០០៩ | កុម្ភៈ ២០១០ | ស្វែងរក NGO |
| ២-ថែរក្សា និង រំលោះព្រៃលិចទឹក | | ថែរក្សា | ថែរក្សា | | | |

## គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ ២៥x២.៥ម | ១៨ស្រះ | ត្រីប្រា | ៧២០០០កូន<br>១ស្រះ=៤០០០កូន | មេសា២០០៩ | មិថុនា ២០០៩ |

## គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រជុំផ្សព្វផ្សាយស្តីពីការដាក់ពាក្យសុំចូលជាសមាជិកនិងប្រមូលប្រាក់វិភាគទានសមាជិកសហគមន | ១/២/២០០៩ | ១/២/២០១០ | ១នាក់=១០០០រ<br>២៣៩០០០រ | |
| ភាគទានប្រចាំឆ្នាំ | ប្រជុំផ្សព្វផ្សាយស្តីពីកាប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | ១/២/២០០៩ | ១/៦/២០១០ | ២៣៩០០០រ | |
| ជំនួយសប្បុរសជន និងអង្គការនានា | គម្រោងទ្រទ្រង់ជីវភាពបរិស្ថានបឹងទន្លេសាប (TSSL) | | | | |

## គ-៧ ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាពសហគមន៍

| ប្រភេទមុខរបរ | សកម្មភាព និងចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ចិញ្ចឹម ត្រី, ជ្រូក, មាន់ | ជួលគ្រូបច្ចេកទេសបង្រៀនស្តីពីការចិញ្ចឹម ជ្រូក, មាន់ ។<br>ជួលគ្រូបច្ចេកទេសបង្រៀនស្តីពីការចិញ្ចឹមត្រី ។<br>មាន់ ៣ក្បាល/គ្រួសារ (១០គ្រួសារ)<br>ជ្រូក២ក្បាល/គ្រួសារ (១០គ្រួសារ) | ១/២/២០០៩ | ១/៣/២០១០ |
| ដាំបន្លែ (ននោង, សណ្តែកគួ, ស្ពៃខៀវ, ស្ពៃចង្កឹះ...) | ជួលគ្រូបច្ចេកទេសបង្រៀនស្តីពីការដាំបន្លែ ។<br>៣០ គ្រួសារ /គ្រួសារផ្តល់ពូជ១គក្រ | ១/៣/២០០៩ | ១/៤/២០១០ |
| បណ្តុះផ្សិត | ជួលគ្រូបច្ចេកទេសបង្រៀនស្តីពីការបណ្តុះផ្សិត ។<br>១គ្រួសារ/២រង (២០គ្រួសារ) | ១/៣/២០០៩ | ១/៤/២០១០ |

### គ-៨ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍

| ចំនួនបង្គោល | ចំណុចត្រូវបោះ | អ្នកទទួលខុសត្រូវ | ពេលវេលា | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ | |
| ៧ បង្គោល | តាមចំណុចដែលបានកំនត់ក្នុងផែនទីសហគមន៍ | គណៈកម្មការសហគមន៍នេសាទ | កុម្ភៈ ២០០៩ | មិនា ២០១០ | ត្រូវការជំនួយ និងការសហការពី ស្ថាប័នជំនាញ និងអង្គការនានា |

### គ-៩ ផែនការផ្សព្វផ្សាយ និងលើកកំពស់ការយល់ដឹង

| ប្រធានបទ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| លក្ខន្តិកៈនិង បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៣ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |
| សារៈប្រយោជន៍នៃធនធានធម្មជាតិ និងបរិស្ថាន | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |
| ផែនទីកំណត់ព្រំប្រទល់កន្លែងនេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៨ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |
| ផែនការគ្រប់គ្រងកន្លែងនេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |
| ច្បាប់ជលផល និងច្បាប់ផ្សេងៗទាក់ទងដល់ការគ្រប់គ្រងសហគមន៍នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |
| ការគ្រប់គ្រង និងសារៈប្រយោជន៍នៃព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |
| ផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុលកសិកម្ម និងការប្រើប្រាស់ឧបរណ៍នេសាទល្មើសច្បាប់ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ២ នៃឆ្នាំនិមួយៗ | រដ្ឋបាលជលផល CFC |

### គ-១០ ផែនការពង្រឹងសមត្ថភាពសហគមន៍

| ផែនការ | ប្រធានបទ/ជំនាញ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ពង្រឹងស្ថាប័ន និងការងារគ្រប់គ្រង | ការធ្វើកំណត់ហេតុ និង របាយការណ៍ | គណៈកម្មការស.ន | កុម្ភៈ ២០០៨ | រដ្ឋបាលជលផល CFC |
| | របៀបសរសេរខិតរដ្ឋបាល | គណៈកម្មការស.ន | កក្កដា ២០០៨ | រដ្ឋបាលជលផល CFC |

| | | | | |
|---|---|---|---|---|
| | រៀបចំទុកដាក់ឯកសារសហគមន៍ និងរបៀបកត់ត្រាប្រចាំថ្ងៃ | គណៈកម្មការស.ន | មិថុនា ២០០៨ | រដ្ឋបាលជលផល CFC |
| | ការគ្រប់គ្រងថវិកា | គណៈកម្មការស.ន | កុម្ភៈ ២០០៨ | រដ្ឋបាលជលផល CFC |
| | ការដោះស្រាយទំនាស់ | គណៈកម្មការស.ន | | រដ្ឋបាលជលផល CFC |
| | ការទំនាក់ទំនង និងសរសេរសំណើសុំថវិកា | គណៈកម្មការស.ន | មេសា ២០០៨ | រដ្ឋបាលជលផល CFC |
| | រៀបចំបណ្ដាញសហគមន៍ | គណៈកម្មការស.ន | សីហា ២០០៨ | រដ្ឋបាលជលផល CFC |
| | ទស្សនៈកិច្ចសិក្សារផ្លាស់ប្ដូរបទពិសោធន៍ | គណៈកម្មការស.ន | ១ដង/ឆ្នាំ | រដ្ឋបាលជលផល CFC |
| បណ្ដុះបណ្ដាលបច្ចេកទេស | បណ្ដុះ និងដាំព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | តុលា ២០០៨ | រដ្ឋបាលជលផល CFC |
| | ចិញ្ចឹមត្រី និងសត្វ | សមាជិក និង គណៈកម្មការស.ន | កុម្ភៈ ២០០៨ | រដ្ឋបាលជលផល CFC |
| | បណ្ដុះផ្សិត | សមាជិក និង គណៈកម្មការស.ន | មិនា ២០០៨ | រដ្ឋបាលជលផល CFC |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្ដល់យោបល់ចំពោះផែនការណាដែល ទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្ដារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរក ថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួល បានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់

- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ កោះឬស្សី រយៈពេល ៣ ឆ្នាំ (២០០៨ ដល់ ២០១០)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | - ផ្សព្វផ្សាយផែនការប្រើប្រាស់ឧបករណ៍នេសាទដល់សមាជិកសហគមន៍ទាំងអស់ និងអ្នកមកពីខាងក្រៅ<br>- ចុះត្រួតពិនិត្យ និងតាមដានជាប្រចាំ | - សមាជិក និងអ្នកមិនមែនជាសមាជិកសហគមន៍ទាំងអស់បានជ្រួតជ្រាបពីផែនការ<br>- ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ នាំឱ្យត្រីមានការកើនឡើង | - ចំណាយលើការផ្សព្វផ្សាយ ១៥០ ដុល្លា<br>- ចំណាយលើការចុះល្បាត ត្រួតពិនិត្យតាមដាន ២០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៩ | មករា ២០១០ | |
| ២. ការកែលំអដែននេសាទ | គ្មាន | | | | | | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | បឹងកេះទំហំ ២៣៥ម×៣៥ម | - ជីវភាពកើនឡើង<br>- ជីវភាពសំបូររុងរឿង<br>- រក្សាមេពូជ | ២០០០ដុល្លារ | -អង្គការ<br>- ជំនាញ | មករា ២០០៩ | មករា ២០១០ | |
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹកមាត់បឹងអន្លង់កេះ | ១៥ម x ១០០០ម រាំង ត្រស់ ចង្កែង ចំនួន ១០០០០កូន | -រក្សាមេពូជត្រី<br>-សំបូរសត្វស្លាប និងធនធានជលផល។<br>- ជីវភាពប្រជាជនកើនឡើង | ៣០០ ដុល្លា | -អង្គការ<br>- ជំនាញ | កុម្ភៈ ២០០៩ | កុម្ភៈ ២០១០ | |
| ៥- ផែនការអភិវឌ្ឍ | ចិញ្ចឹមត្រីប្រា១៨ ស្រះ | -ជីវភាពប្រជាជនកើនឡើង<br>-បង្កើនជីវភាពគ្រួសារ | ២០០០ ដុល្លា | សប្បុរសជន | មិថុនា | ធ្នូ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| នីវារីវប្បកម្ម | ចំនួន ៧២០០០កូន | | | - អង្គការ និង ជំនាញ | ២០០៩ | ២០១០ | |
| ៦- ផែនការរកប្រាក់ចំណូលសហគមន៍ | - ប្រមូលប្រាក់សមាជិកភាព និង ភាគទានប្រចាំឆ្នាំ<br>- ស្វែងរកជំនួយបន្ថែមពីអង្គការ និងសប្បុរសជននានា | សមាជិកស.នទាំងអស់នឹងបង់ប្រាក់តាមការកំនត់ក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>អង្គការ និងសប្បុរសជននានា នឹងជួយគាំទ្រតាមរយៈការផ្តល់សំភារៈ និងថវិកាដល់ស.ន | - គ្មានការចំណាយ | - | មេសា ២០០៩ | មេសា ២០១០ | |
| ៧- ផែនការបង្កើនមុខរបរ ទ្រទ្រង់ជីវភាព | - វិភាគ និងចាត់អាទិភាព ជំរើស មុខរបរចិញ្ចឹមជីវិត<br>- ស្វែងរកអង្គការ ស្ថាប័នគាំទ្រ<br>- រៀបចំសំណើសុំថវិកា | - ជំរើសមុខរបរចិញ្ចឹមជីវិតត្រូវបានកំនត់ និងចាត់អាទិភាព<br>- សំណើសុំថវិកាត្រូវបានរៀបចំ និងទទួលបានការគាំទ្រពីអង្គការនានា | - ចំណាយសរុប ៥០០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មិនា ២០០៩ | មិនា ២០១០ | |
| ៨- ផែនការបោះបង្គោល ព្រំប្រទល់សហគមន៍ | សហការជាមួយជំនាញផែនទីកំនត់ទីតាំងត្រូវបោះបង្គោល<br>- ស្វែងរកថវិកាគាំទ្រ | បង្គោលត្រូវបានបោះត្រឹមត្រូវតាមចំនុចដែលកំនត់លើផែនទី<br>- ស.នមានព្រំប្រទល់ច្បាស់លាស់ កាត់បន្ថយជម្លោះ | - ចំណាយសរុប ៣០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | កុម្ភៈ ២០០៩ | មិនា ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩- ផែនការផ្សព្វផ្សាយ និងបង្កើនការយល់ដឹង | - ផ្សព្វផ្សាយឱ្យស.គបានយល់ដឹងពី លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធ និងស.ន | - ស.គបានយល់ដឹង និងអនុវត្តតាម | - ១០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៩ | ធ្នូ ២០១០ | |
| ១០- ផែនការពង្រឹងសមត្ថភាពសហគមន៍ | - បង្កើនសមត្ថភាពស.គទាំងជំនាញ គ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | - ស.គចេះជំនាញផ្សេងៗទាក់ទិន និងការងារគ្រប់គ្រងស្ថាប័ន និង បច្ចេកទេស | - ១០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៩ | ធ្នូ ២០១០ | |

តារាងកម្មវិធីការងារ

| សកម្មភាព | ឆ្នាំ ២០០៨ | | | | | | | | | | | | ឆ្នាំ ២០០៩ | | | | | | | | | | | | ឆ្នាំ ២០១០ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២. ការកែលំអដែននេសាទ | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៨. ផែនការបោះបង្គោលព្រំប្រទល់ស.គ | | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩. ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ១០. ផែនការពង្រឹងសមត្ថភាពសហគមន៍ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | |

បានឃើញ និងបញ្ជូនមក
លោកនាយ[illegible]រដ្ឋបាលជលផល
**នាយសង្កាត់រដ្ឋបាលជលផល**...[illegible]...
...........ថ្ងៃទី.....10.....ខែ.....10.........ឆ្នាំ ២០០8

លេខ :.................

បានឃើញ
**មេឃុំ**...[illegible]...
...............ថ្ងៃទី ...[illegible]... ខែ ...[illegible]... ឆ្នាំ ២០០[illegible]

ឆោ_ស៊ីម

លេខ :...376...[illegible]...

ទួលសាលា...ថ្ងៃទី......10.......ខែ......10.........ឆ្នាំ ២០០8
**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ :..02...[illegible]...

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី...........ខែ.............ឆ្នាំ ២០០
**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "
...........ថ្ងៃទី...[illegible]...ខែ...11.........ឆ្នាំ ២០០8
**នាយអធិការដ្ឋាន[illegible]រដ្ឋបាលជលផល**...[illegible]...

បានឃើញ និងបញ្ជូនមក
លោកនាយអធិការដ្ឋាន[illegible]រដ្ឋបាលជលផល.........
...........ថ្ងៃទី...21...ខែ...10...ឆ្នាំ ២០០8
**នាយខណ្ឌរដ្ឋបាលជលផល**...[illegible]...